# ការអនុវត្តន៍ល្អ

## សុវត្ថិភាពឃ្លាំង: កំពស់ស្តុក

រោងចក្រ
កាន់តែប្រសើរ
នៅកម្ពុជា

ដើម្បីធ្វើអោយរោងចក្រកាន់តែមានសុវត្ថិភាព និងផលិតភាពកាន់តែប្រសើរ កន្លែងស្តុកចាំបាច់ត្រូវរៀបចំអោយមានប្រសិទ្ធិភាព និងសុវត្ថិភាព។ ធានាថាប្រអប់ និងសំភារៈទាំងអស់ត្រូវបានតំរៀបយ៉ាងត្រឹមត្រូវហើយធានាថា កំពស់ស្តុកត្រូវបានកំណត់ និងត្រួតពិនិត្យ ។

### ការអនុវត្តន៍ល្អសំរាប់ការស្តុកដែលមានសុវត្ថិភាពនៅក្នុងឃ្លាំង

កំណត់កំពស់ស្តុកអតិបរិមា ដោយប្រើកំណាត់ឈើជាសំគាល់ (រូបភាពទី១) ។

ឬ គូសបន្ទាត់ពណ៌ក្រហម នៅលើជញ្ជាំងដើម្បីចង្អុលបង្ហាញពីកំពស់ស្តុក ដែលមានសុវត្ថិភាព (រូបភាពទី២) ។

ត្រួតពិនិត្យមើលជាប្រចាំថា ប្រអប់ឥវ៉ាន់ទាំងឡាយត្រូវបានរៀបយ៉ាងត្រឹមត្រូវ ហើយប្រអប់ឥវ៉ាន់ឬសំភារៈមិនត្រូវបានរៀបអោយហួសពីកំពស់ដែលបានដាក់សញ្ញាសំគាល់ឡើយ ។


រូបភាពទី១


រូបភាពទី២

### អត្ថប្រយោជន៍:

- ✓ បង្ហាញទស្សនៈនៃកន្លែងធ្វើការល្អ
- ✓ បង្កើតកន្លែងធ្វើការដែលកាន់តែមានសុវត្ថិភាព
- ✓ កាត់បន្ថយគ្រោះថ្នាក់នៅកន្លែងធ្វើការងារ
- ✓ លើកកំពស់ការយល់ដឹងពីការអនុវត្តន៍ប្រកបដោយសុវត្ថិភាព
- ✓ លើកកំពស់ប្រសិទ្ធិភាពរបស់ឃ្លាំង

### តាមរបៀបណា:

- ✓ ប្រើប្រាស់កំណាត់ឈើជាសញ្ញាសំគាល់ ឬ
- ✓ គូសបន្ទាត់ដើម្បីបង្ហាញកំពស់ស្តុកអតិបរមា

### តំលៃ:

$

- $ តំលៃទាប
- $$ តំលៃមធ្យម
- $$$ តំលៃខ្ពស់


អង្គការ
ពលកម្ម
អន្តរជាតិ

ប្រសិនបើលោកអ្នកមានសំនួរ សូមទាក់ទងមកអង្គការពលកម្មអន្តរជាតិតាមរយៈអ៊ីម៉េល betterfactories@ilo.org